**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ០៧៤៥ សហវ.ប្រក

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០១១

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការកំណត់កម្រៃសេវាកម្មចំពោះការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ អាជ្ញាប័ណ្ណប្រើសញ្ញាស្តង់ដារកម្ពុជា អាជ្ញាប័ណ្ណចុះបញ្ជីផលិតផល និងលិខិតបញ្ជាក់មុខសញ្ញា និង/ឬស្តង់ដារប្រើប្រាស់សារធាតុគីមីក្នុងវិស័យឧស្សាហកម្ម

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីស្តង់ដារកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានស្តង់ដារកម្ពុជា
- បានឃើញបទបញ្ជារាជរដ្ឋាភិបាលលេខ ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងតាមតម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ស ម្រេ ច

**ប្រការ ១ :** អនុញ្ញាតឱ្យយកកម្រៃសេវាកម្ម ចំពោះការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ អាជ្ញាប័ណ្ណប្រើសញ្ញាស្តង់ដារកម្ពុជា អាជ្ញាប័ណ្ណចុះបញ្ជីផលិតផល និងលិខិតបញ្ជាក់មុខសញ្ញា និង/ឬស្តង់ដារប្រើប្រាស់សារធាតុគីមីក្នុងវិស័យឧស្សាហកម្ម ដែលផ្តល់ដោយវិទ្យាស្ថានស្តង់ដារកម្ពុជានៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ ២ :** កម្រៃសេវាកម្មត្រូវបានកំណត់ចំពោះការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ អាជ្ញាប័ណ្ណប្រើសញ្ញាស្តង់ដារកម្ពុជា អាជ្ញាប័ណ្ណចុះបញ្ជីផលិតផល និងលិខិតបញ្ជាក់មុខសញ្ញា និង/ឬស្តង់ដារប្រើប្រាស់សារធាតុគីមីក្នុងវិស័យឧស្សាហកម្មមានដូចខាងក្រោម :

| ល.រ | ប្រភេទសេវាកម្ម | កម្រៃសេវាកម្ម | សុពលភាព |
|---|---|---|---|
| ១ | វិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ: - GMP/GHP | ៨០០ ០០០ រៀល | ៣ឆ្នាំ |
| | - HACCP | ១ ៦០០ ០០០ រៀល | ៣ឆ្នាំ |
| | - ISO 9000 ឬ ISO 14000 | ២ ០០០ ០០០ រៀល | ៣ឆ្នាំ |
| | - ISO 22000 | ២ ៤០០ ០០០ រៀល | ៣ឆ្នាំ |
| ២ | អាជ្ញាប័ណ្ណប្រើសញ្ញាស្តង់ដារកម្ពុជា | ៨០០ ០០០ រៀល | ៣ឆ្នាំ |
| ៣ | អាជ្ញាប័ណ្ណចុះបញ្ជីផលិតផល | ៦០០ ០០០ រៀល | ៣ឆ្នាំ |
| ៤ | លិខិតបញ្ជាក់មុខសញ្ញា និង/ឬស្តង់ដារប្រើប្រាស់សារធាតុគីមី : | | |
| | -តម្លៃនាំចូលតិចជាង ៥០ ០០០ ០០០ រៀល | ៦០០ ០០០ រៀល | |
| | -តម្លៃនាំចូលចាប់ពី ៥០ ០០០ ០០១ រៀល ដល់ ៥០០ ០០០ ០០០ រៀល | ១ ០០០ ០០០ រៀល | |
| | - តម្លៃនាំចូលច្រើនជាង ៥០០ ០០០ ០០០ រៀល | ១ ៤០០ ០០០ រៀល | |

**ប្រការ ៣ :** ការគ្រប់គ្រងចំណូលពីកម្រៃសេវាកម្ម ដូចមានចែងក្នុងប្រការ២ខាងលើ ត្រូវអនុវត្តតាមនីតិវិធីនៃកិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ ។ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងមន្ទីរ អង្គភាពក្រោមឱវាទក្រសួង ត្រូវបង់ចំណូលដែលប្រមូលបានចូលថវិការដ្ឋ និងធ្វើរបាយការណ៍ពីចំណូលប្រចាំខែ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ) ឱ្យបានទៀងទាត់ ។

**ប្រការ ៤ :** ការបង់ប្រាក់កម្រៃសេវាកម្ម ដូចមានចែងក្នុងប្រការ២ខាងលើ ត្រូវអនុវត្តតាមរយៈរជ្ជទេយ្យករចំណូល ។

**ប្រការ ៥ :** ការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តទៅដល់អង្គភាពប្រមូលចំណូល នឹងត្រូវចែងលម្អិតក្នុងប្រកាសអន្តរក្រសួងមួយដោយឡែក បន្ទាប់ពីមានគោលការណ៍ពីរាជរដ្ឋាភិបាល ។

**ប្រការ ៦ :** តារាងកម្រៃសេវាកម្ម ត្រូវបិទប្រកាសផ្សព្វផ្សាយនៅនឹងអង្គភាពប្រមូលចំណូល ។

**ប្រការ ៧ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៨ :** គ្រប់អង្គភាពក្រោមឱវាទក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ ៩ :** ប្រកាសអន្តរក្រសួងនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រី**
**ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**ស៊ុយ សែម**

ចម្លងជូន :
- ខុទ្ទកាល័យព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- គ្រប់សាលារាជធានី-ខេត្ត
  " ដើម្បីជូនជ្រាប "
- ដូចប្រការ៨ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ